00238547

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception):
07 / 03 / 2011
ម៉ោង (Time/Heure): 10:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

C22/4

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**

**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**
**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 002/19-09-2007-ECCC-OCIJ**

# ដីកាសម្រេចអំពីការបន្តរយៈពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

# Order on Extension of Provisional Detention
# Ordonnance sur la prolongation de la détention provisoire

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

បានឃើញច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពី អ.វ.ត.ក.")

បានឃើញវិធាន ៦៣(៧) នៃវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ

បានឃើញការបើកការស៊ើបសួរលើឈ្មោះ **អៀង សារី**
ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះ **ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៥ មាត្រា៦ មាត្រា២៩ (ថ្មី) និងមាត្រា៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក.


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

បានឃើញដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧

បានឃើញសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨

បានឃើញសេចក្ដីជូនដំណឹងចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៨ ដែលក្នុងនោះយើងបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួន អំពីគោលបំណងរបស់យើងក្នុងការបន្តថេរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលនឹងត្រូវផុតរលត់នៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៨ ហើយនិងបានឲ្យជាដំណឹងដល់ពួកគេថា ពួកគេមានរយៈពេល ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ ឬតវ៉ាមកយើង

បានឃើញការតវ៉ាជំទាស់របស់ក្រុមមេធាវីការពារក្ដីរបស់ជនត្រូវចោទ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨។

**ការរំលឹកឡើងវិញអំពីនីតិវិធី**

១. នាថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ សហព្រះរាជអាជ្ញាបានចេញនូវដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលក្នុងនោះសហព្រះរាជអាជ្ញាបានបង្ហាញឈ្មោះ អៀង សារី និងជនសង្ស័យចំនួនបួននាក់ផ្សេងទៀត ថាបានប្រព្រឹត្តបទឧក្រិដ្ឋ ដែលឋិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ[1]។

២. នាថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ អៀង សារី អំពីការដាក់ជននេះឲ្យឋិតនៅក្រោមការពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើ អមនុស្សធម៌ផ្សេងៗទៀត) និងការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩ (ការធ្វើមនុស្សឃាតដោយចេតនា ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមាន ការឈឺចាប់ដល់

[1] D3 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧។

រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិ ទទួលបានការកាត់ទោសដោយយុត្តិធម៌ ការនិរទេស ការជម្លៀស ឬការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់[2]។

៣. នាថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ បន្ទាប់ពីមានការជជែកតទល់ សហចៅក្រមស៊ើបអង្កេតបានសម្រេចឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី ក្នុងថេរៈវេលាអតិបរមាចំនួនមួយឆ្នាំ[3]។

៤. នាថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០០៧ អៀង សារី បានធ្វើបណ្ដឹង ឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន[4]។ បន្ទាប់ថ្ងៃសវនាការ ដែលប្រព្រឹត្តឡើងនៅថ្ងៃទី ៣០ មិថុនា និង ថ្ងៃទី០១ ទី០២ និងទី០៣ កក្កដា ឆ្នាំ ២០០៨ អង្គបុរេជំនុំជម្រះ បានយល់ស្របជាឯកច្ឆ័ន្ទលើដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ហើយដែលសំអាងហេតុ ដែលមានក្នុងដីការបស់សហចៅក្រមស៊ើបអង្កេត ត្រូវបានជំនួសដោយសំអាងហេតុ ដែលមានក្នុងសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ[5]។

៥. នាថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ខ្លួនថា សហចៅក្រមស៊ើបអង្កេតគ្រោងនឹងធ្វើការបន្តថេរៈវេលានៃការឃុំខ្លួន អៀង សារី ហើយថាពួកគេមានថេរៈវេលា ១៥ ថ្ងៃ ដើម្បីធ្វើការកត់សម្គាល់ និងតវ៉ា[6]។

៦. នាថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨ សហមេធាវីរបស់ អៀង សារី បានដាក់នូវការកត់សម្គាល់របស់ខ្លួន ដោយទាមទារឱ្យសហចៅក្រមស៊ើបអង្កេតសម្រេចដោះលែងកូនក្ដីរបស់ខ្លួនឱ្យ

---

[2] C12/I កំណត់ហេតុនៃការនាំខ្លួន អៀង សារី ចុះថ្ងៃទី ១២ វិច្ឆិកា ឆ្នាំ ២០០៨។

[3] C22 ដីកាសម្រេចឱ្យមានការឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧។

[4] C22/I/5 បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ធ្វើនៅថ្ងៃទី១២ ធ្នូ ២០០៧។

[5] C22/I/73 អង្គបុរេជំនុំជម្រះ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨។

[6] C22/2 ការជូនដំណឹង (វិធាន ៦៣.៧) ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០០៨។

មានសេរីភាព ឬធ្វើការជំនួសការឃុំខ្លួន ដោយការឃុំខ្លួននៅក្នុងគេហដ្ឋាន ក្នុងលក្ខខណ្ឌ ដែលស្របទៅនឹងគោលបំណងនៃវិធាន ៦៣ នៃវិធានផ្ទៃក្នុង[7]។

## ការរំលឹកឡើងវិញអំពីច្បាប់ដែលត្រូវអនុវត្ត

៧. កថាខណ្ឌ ៦ និង ៧ នៃវិធាន ៦៣ នៃវិធានផ្ទៃក្នុង បានផ្តល់អំណាចឱ្យសហចៅក្រមស៊ើបអង្កេត ក្នុងការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន៖

វិធាន ៦៣.៦. នៃវិធានផ្ទៃក្នុង ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងដូចខាងក្រោម៖

ក) ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ថេរៈវេលានៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពីមួយឆ្នាំបានទេ។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបន្ថែមម្តងបានមួយឆ្នាំ។

វិធាន ៦៣.៧. នៃវិធានផ្ទៃក្នុង ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ត្រូវធ្វើជាលាយល័ក្ខអក្សរ ហើយត្រូវមានសំអាងហេតុ ចំពោះការពន្យាពេលនៃការបន្តឃុំខ្លួនបណ្តោះអាសន្ន។ ការពន្យាពេលនៃការឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើបានតែក្នុងករណី ដែលសហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ជនត្រូវចោទ និងមេធាវីរបស់ជនត្រូវចោទ ហើយត្រូវផ្តល់រយៈពេល ១៥ ថ្ងៃ ដើម្បីទុកពេលឱ្យតវ៉ាទៅសហចៅក្រមស៊ើបអង្កេត។ ទោះជាយ៉ាងណាក៏ដោយ ការពន្យាពេលមិនត្រូវឱ្យលើសពីពីរដងបានឡើយ។ ដីកាសម្រេចនេះបើកផ្លូវប្តឹងឧទ្ធរណ៍។

៨. សហចៅក្រមស៊ើបអង្កេត អាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបាន តែកាលណាលក្ខខណ្ឌ ដែលកំណត់នៅក្នុង វិធាន ៦៣.៣. ត្រូវបានបំពេញតែប៉ុណ្ណោះ៖

---

[7] ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តីប្រឆាំងនឹងការបន្តការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ២៨ តុលា ២០០៨។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ក) មានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់យ៉ាងច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយ ឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។

ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បី៖

i. រារាំងកុំឱ្យជនដែលត្រូវចោទនោះគាបសង្កត់ទៅលើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិតចំពោះបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ។

ii. ថែរក្សាភស្តុតាង ឬការពារមិនឱ្យបំផ្លាញភស្តុតាង។

iii. ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី។

iv. ការពារសន្តិសុខឱ្យជនដែលត្រូវចោទ ឬ

v. រក្សាសណ្ដាប់ធ្នាប់សាធារណៈ។

៩. នៅក្នុងសេចក្ដីសម្រេចចំពោះបណ្ដឹងឧទ្ធរណ៍ ដែលធ្វើឡើងដោយ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អង្គបុរេជំនុំជម្រះ បានធ្វើការកំណត់និយមន័យចំពោះពាក្យថា "មូលហេតុដែលត្រូវបានរកឃើញ" ស្របតាមខ្លឹមសារនៃវិធាន ៦៣.៣[8]៖

ដូចតុលាការព្រហ្មទណ្ឌអន្តរជាតិធ្លាប់បានអនុវត្ត អង្គបុរេជំនុំជម្រះនឹងធ្វើការបកស្រាយពាក្យថា "មូលហេតុដែលត្រូវបានរកឃើញ" ដោយធ្វើការស្វែងរកបទដ្ឋានណែនាំ នៅក្នុងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបស្ដីពីសិទ្ធិមនុស្ស។ នេះមានន័យថា អង្គបុរេជំនុំជម្រះត្រូវតែធ្វើការវិនិច្ឆ័យថា តើមានអង្គហេតុ ឬព័ត៌មាន ដែលនឹងធ្វើឱ្យអ្នកសង្កេតការដែលមិនលំអៀងជឿថា បុគ្គលដែលពាក់ព័ន្ធធ្លាប់បានប្រព្រឹត្តបទល្មើសមែនដែរ ឬទេ។

---

[8] C11/54 អង្គបុរេជំនុំជម្រះ សេចក្ដីសម្រេចចំពោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន នួន ជា ២០ មីនា ២០០៨ កថាខណ្ឌ ៤៦។

00238552



## ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្ដី

១០. នៅក្នុងបណ្ដឹងតវ៉ារបស់ខ្លួន[9] អៀង សារី បានបកស្រាយថា៖

ក) សហចៅក្រមស៊ើបអង្កេតមានកាតព្វកិច្ចក្នុងការផ្ដល់នូវសំអាងហេតុ និងសំអាងច្បាប់ឲ្យបានពិស្ដារ ចំពោះរាល់ការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ឬការរក្សាបន្តការឃុំខ្លួន។ ជនជាប់ឃុំអាចធ្វើបណ្ដឹងឧទ្ធរណ៍ដោយត្រឹមត្រូវតាមទំរង់ និងប្រកបដោយសមធម៌បាន ទាល់តែដីកាសម្រេចទាំងអស់មានបរិយាយពិស្ដារអំពីហេតុផល។
ខ) ការសម្រេចឃុំខ្លួនបណ្ដោះអាសន្ន អាចនឹងបង្គាប់ឲ្យមាន ប្រសិនបើវាជាវិធានការចាំបាច់តែប៉ុណ្ណោះ។ សហចៅក្រមស៊ើបអង្កេតមិនត្រូវផ្ដល់អាទិភាពឲ្យការឃុំខ្លួនបណ្ដោះអាសន្នជាងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះឡើយ ប្រសិនបើវិធានការទាំងនេះវាមានលក្ខណៈគ្រប់គ្រាន់ក្នុងការសម្រេចបាននូវគោលដៅនៃការឃុំខ្លួន។
គ) ប្រសិនបើអនុវត្តឲ្យត្រឹមត្រូវនូវលក្ខណៈវិនិច្ឆ័យ នៃវិធាន ៦៣.៣.ខ). ទាក់ទងនឹងការឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី នឹងត្រូវដោះលែងឲ្យមានសេរីភាព និងដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ។

# ហេតុផលនៃសេចក្ដីសម្រេច

## វិធាន ៦៣.៣.ក. នៃវិធានផ្ទៃក្នុង

១១. នៅក្នុងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០០៧ សហចៅក្រមស៊ើបអង្កេតគិតថាវាពិតជាមានហេតុផល ដែលនាំឲ្យជឿជាក់ច្បាស់ថា ជនត្រូវចោទធ្លាប់បានប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលខ្លួនគាត់ត្រូវបានចោទប្រកាន់។ នៅក្នុងបណ្ដឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានធ្វើការ

[9] C22/3 ការកត់សម្គាល់របស់ក្រុមមេធាវីការពារក្ដីប្រឆាំងនឹងការបន្តការឃុំខ្លួនបណ្ដោះអាសន្ន អៀង សារី ២៨ តុលា ២០០៨ កថាខណ្ឌ ០១។



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

វិភាគយ៉ាងល្អិតល្អន់ លើសំណុំរឿង ដែលមាននៅក្នុងថ្ងៃសវនាការ[10]។ អង្គបុរេជំនុំជម្រះបានសម្រេចយកជាបានការនូវភស្តុតាងដូចខាងក្រោម៖

ក) តាមរយៈការប្រកាសផ្សេងៗ អៀង សារី បានទទួលស្គាល់ថា ខ្លួនធ្លាប់ជារដ្ឋមន្ត្រីក្រសួងការបរទេស និងជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ នៃបក្សកុម្មុយនីស្តកម្ពុជា[11]

ខ) ការប្រកាសរបស់ជនត្រូវចោទផ្សេងទៀត ជាពិសេសរបស់ [លុប] ហើយបានអះអាងថា អៀង សារី ជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការអចិន្ត្រៃយ៍[12]។

គ) បញ្ជីឈ្មោះអ្នកទោស ដែលជាប់ឃុំនៅមន្ទីរ ស-២១ បង្ហាញថាមនុស្សជាង ១០០ នាក់ត្រូវបានចាប់ខ្លួនពីក្រសួងការបរទេស[13]។

ឃ) សៀវភៅរបស់ Laurence PICQ ដែលកាលនោះធ្វើការនៅក្នុងក្រសួងការបរទេស ហើយបាននិយាយថា គាត់ធ្លាប់បានឃើញ អៀង សារី ក្នុងពេលប្រជុំ ហើយជននេះបានជំរុញឲ្យអ្នកចូលរួមបង្ហាញអំពីជនក្បត់[14]។

ង) ឯកសារផ្សេងៗ ដែលមានដូចជាកំណត់ហេតុនៃសន្ទនកថា ដែលធ្វើឡើងដោយ អៀង សារី ហើយក្នុងនោះមានការអំពាវនាវឲ្យ "កំទេច" ខ្មាំង សេចក្តីណែនាំនៃគណៈកម្មាធិការមជ្ឈិម កំណត់ហេតុនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងចម្លើយសារភាពរបស់មន្ត្រីរាជការនៃក្រសួងការបរទេស ដែលត្រូវបានចុះហត្ថលេខានៅមន្ទីរ ស-២១ និងបញ្ជូនទៅ អៀង សារី[15]។

១២. ដោយពិនិត្យទៅលើមូលដ្ឋាននៃភស្តុតាងទាំងនេះ អង្គបុរេជំនុំជម្រះបានធ្វើការសន្និដ្ឋានថា សំណុំរឿង៖

---

[10] ថ្ងៃទី ៣០ មិថុនា និង ថ្ងៃទី ០១ ទី០២ និងទី០៣ កក្កដា ២០០៨។

[11] C22/73 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ៧៥ និង ៧៦។

[12] ដូចខាងលើ កថាខណ្ឌ ៧៥-៧៧។

[13] ដូចខាងលើ កថាខណ្ឌ ១៣។

[14] ដូចខាងលើ កថាខណ្ឌ ៩៣។

[15] ដូចខាងលើ កថាខណ្ឌ ៨២ ៨៧ និង ៩២។

...មានភស្តុតាង ដែលអាចធ្វើឲ្យអ្នកសង្កេតការណ៍ដោយមិនលំអៀងជឿថា នៅត្រឹមដំណាក់កាលនៃការស៊ើបអង្កេតនេះ ជនត្រូវចោទធ្លាប់បានប្រព្រឹត្តបទល្មើស ដែលខ្លួនត្រូវបានចោទប្រកាន់។ ដូច្នេះ អង្គបុរេជំនុំជម្រះយល់ឃើញថាលក្ខខណ្ឌតម្រូវនៃវិធាន ៦៣.៣. ត្រូវបានបំពេញ[16]។

១៣. ចាប់តាំងពីថ្ងៃសវនាការនៃបណ្តឹងឧទ្ធរណ៍នោះមក សហចៅក្រមស៊ើបអង្កេតនៅតែបន្តកិច្ចស៊ើបសួររបស់ខ្លួន ចំពោះបទចោទប្រកាន់ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររហូតមក។ ប៉ុន្តែនៅក្នុងសំណុំរឿង មិនទាន់មានភស្តុតាងថ្មីណា ដែលផ្ទុយទៅនឹងភស្តុតាង ដែលអង្គបុរេជំនុំជម្រះយកមកធ្វើជាមូលដ្ឋាននៃសេចក្តីសម្រេចរបស់ខ្លួននៅឡើយទេ ជាហេតុធ្វើឲ្យសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅតែមានសុពលភាព។ ផ្ទុយទៅវិញ សាក្សីឈ្មោះ [លុប] បានបញ្ជាក់គាំទ្រលើការចោទប្រកាន់ទាំងនេះ[17]។

១៤. ដោយហេតុថា ការសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះលើសំណុំរឿងនេះ នៅថ្មីៗនៅឡើយ សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាមិនជាការចាំបាច់ទេ ដែលត្រូវធ្វើការបកស្រាយលើមូលដ្ឋាននៃភស្តុតាងសំខាន់ផ្សេងៗទៀត ដោយគ្រាន់តែធ្វើការកត់សម្គាល់ថា អង្គបុរេបានធ្វើការវិភាគនេះ ហើយចាប់យកចំនុចសង្ខេប ដែលដាក់បន្ទុកលើ អៀង សារី។

១៥. សហចៅក្រមស៊ើបអង្កេតបញ្ជាក់ថា អៀង សារី មិនធ្លាប់បានធ្វើការបដិសេធទេ ចំពោះហេតុដែលថា ភស្តុតាងដែលមាននៅក្នុងសំណុំរឿងគឺវាគ្រប់គ្រាន់សម្រាប់ការអនុវត្តបញ្ញត្តិនៃមាត្រា ៦៣.៣.ក).។

១៦. ដោយសារហេតុផលទាំងនេះ និងបន្ទាប់ពីបានពិនិត្យលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងទាំងអស់ សហចៅក្រមស៊ើបអង្កេតធ្វើសេចក្តីសន្និដ្ឋានថា នៅត្រឹមដំណាក់កាលនៃកិច្ចស៊ើបសួរនេះ

---

[16] ដូចខាងលើ កថាខណ្ឌ ៩៥។

[17] [លុប]

ភស្តុតាងដែលប្រមូលបានទាំងអស់ អាចនឹងធ្វើឱ្យអ្នកសង្កេតការមិនលំអៀងជឿបានថា អៀង សារី ក្នុងនាមជារដ្ឋមន្ត្រីក្រសួងការបរទេស បាន៖

ក) ប្រើប្រាស់អំណាច និងការគ្រប់គ្រងលើក្រសួងការបរទេស និងស្ថាប័ននៅក្រោមចំណុះ

ខ) ក្នុងនាមជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា បានជម្រុញ បញ្ជា ខកខានក្នុងការបង្ការ និងផ្តន្ទាទោស ឬជួយ និងលើកទឹកចិត្តដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលខ្លួនត្រូវបានចោទប្រកាន់។

១៧. ជាងនេះទៅទៀត ត្រូវកត់សម្គាល់ថា បទឧក្រិដ្ឋកម្មដែលចោទប្រកាន់លើ អៀង សារី ត្រូវបានប្រព្រឹត្តិឡើងក្នុងបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ រវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងក្នុងក្របខណ្ឌនៃការវាយប្រហារជាលក្ខណៈប្រព័ន្ធ និងរីករាលដាលប្រឆាំងនឹងប្រជាជនស៊ីវិល។

**វិធាន ៦៣.៣.ខ. នៃវិធានផ្ទៃក្នុង**

១៨. ត្រូវធ្វើការកត់សម្គាល់ថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្នអាចធ្វើទៅបាន ប្រសិនណាបើលក្ខខណ្ឌណាមួយ ដែលកំណត់ក្នុងវិធាណ ៦៣.៣.ខ. ត្រូវបានបំពេញ។ លើសពីនេះ ត្រូវកត់សម្គាល់ទៀតថា សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ច្បាស់ជាមួយ អៀង សារី ហើយថា ការសម្រេចឃុំខ្លួនបណ្តោះអាសន្ន អាចធ្វើទៅបាន ប្រសិនណាបើវាជាវិធានការចាំបាច់ ដើម្បីសម្រេចគោលដៅនៃវិធាន ៦៣.៣.ខ. តែប៉ុណ្ណោះ។ ដូច្នេះប្រសិនណាបើគោលដៅនេះអាចត្រូវបានសម្រេចដោយមធ្យោបាយណាផ្សេងទៀតបាន នោះមធ្យោបាយទាំងនោះនឹងត្រូវទុកក្នុងការពិចារណា។

១៩. មុននឹងធ្វើការពិនិត្យលើគោលបំណងនៃវិធាន ៦៣.៣.ខ. សហចៅក្រមស៊ើបអង្កេតធ្វើការកត់សម្គាល់ថា អង្គបុរេជំនុំជម្រះបានធ្វើការពនិត្យយ៉ាងលំអិតនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនរួចទៅហើយ។ ទោះបីវាជាការចាំបាច់ដែលត្រូវធានាអំពីចរិតលក្ខណៈចាំបាច់នៃការបន្តការឃុំខ្លួនបណ្តោះអាសន្ន ក្នុងពេលដែលដីកាដំបូងត្រូវផុតរលត់នោះក្តី ក៏សហចៅក្រមស៊ើបអង្កេតនៅតែយល់ស្រប និង



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkao Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkao, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ដើរតាមការសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ។ ដើម្បីជាមូលដ្ឋានក្នុងការសម្រេច ចៅក្រមទាំងប្រាំនៅក្នុងអង្គបុរេជំនុំជម្រះយោងទៅលើសារណារបស់ភាគី និងទឡ្ហីករណ៍ផ្សេងៗ ដែលភាគីបានលើកឡើងដោយផ្ទាល់មាត់ក្នុងអំឡុងពេលបួនថ្ងៃនៃសវនាការ ហើយថែមទាំងមានលទ្ធភាពក្នុងការពិនិត្យភស្តុតាងក្នុងសំណុំរឿង ដែលពាក់ព័ន្ធជាពិសេសជាមួយនឹងការឃុំខ្លួនបណ្តោះអាសន្នទៀតផង ហើយវាសុទ្ធតែជាភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតមិនបានទទួលទេនៅក្នុងខែ វិច្ឆិកា ឆ្នាំ ២០០៧ នោះ។

២០. ជាធម្មតា ប្រសិនណាបើសហចៅក្រមស៊ើបអង្កេតបានទទួលភស្តុតាងថ្មីបន្ថែម ដែលអង្គបុរេជំនុំជម្រះមិនទាន់ទទួលបាន ហើយដែលអាចនាំឱ្យគិតថាមានការផ្លាស់ប្តូរកាលៈទេសៈ អ្វីៗដែលបានលើកឡើងខាងលើត្រូវតែពិនិត្យឡើងវិញ។ ផ្ទុយទៅវិញ នៅក្នុងរឿងនេះ វាមិនមានទេ។

*ធានាអំពីវត្តមានរបស់ជនត្រូវចោទនៅក្នុងដំណើរការនីតិវិធី*

២១. បើពិនិត្យតាមភស្តុតាងដែលមានក្នុងសំណុំរឿង យើងសង្កេតឃើញថា៖

ក) អៀង សារី បានរស់នៅក្រុងប៉ៃលិន ហើយខ្លួនគាត់ផ្ទាល់បានស្គាល់អភិបាល និងអភិបាលរងក្រុង ដែលអាចជួយគាត់បាន ប្រសិនបើគាត់ចង់រត់គេចខ្លួនទៅប្រទេសថៃ[18]។

ខ) យើងអាចធ្វើការសន្និដ្ឋានដោយសមហេតុផល តាមរយៈការធ្វើដំណើរនៅក្នុងអតីតកាលថា រូបគាត់មានមធ្យោបាយហិរញ្ញវត្ថុ ដែលអាចជួយសម្រួលដល់ការរត់គេចខ្លួនរបស់គាត់[19]។

[18] C22/I/73 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, 00232830-00232861 (អង់គ្លេស) កថា. ១០២។

[19] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១០៣។

គ) អៀង សារី កាន់លិខិតឆ្លងដែនមួយ ឬច្រើន ក្នុងនោះមានលិខិតឆ្លងដែនមួយដែលមិនមែនចេញដោយប្រទេសកម្ពុជា និងដោយប្រើឈ្មោះផ្សេង ជាមួយនឹងទីកន្លែង និងថ្ងៃខែឆ្នាំកំណើតមិនត្រឹមត្រូវ។ គាត់មានមិត្តភក្តិនៅបរទេស ដែលអាចជួយគាត់ឲ្យចាកចេញពីប្រទេសកម្ពុជាផងដែរ[20]។

ឃ) វាជាការពិតដែល អៀង សារី អាចរត់គេចខ្លួនមុនពេលចាប់ខ្លួនគាត់ប្រសិនបើគាត់ចង់ធ្វើ ប៉ុន្តែគាត់មិនបានធ្វើទេ ប៉ុន្តែនេះមិនធានាថាគាត់មិនរត់គេចខ្លួននៅពេលនេះទេ។ ស្ថានភាពនៅពេលបច្ចុប្បន្ននេះ មិនដូចពីមុនទេ ពីព្រោះគាត់ស្ថិតនៅក្រោមកិច្ចស៊ើបសួរ[21]។

២២. ដោយហេតុផលនេះ អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា វាជាការចាំបាច់ដែលអះអាងទទួលស្គាល់ការឃុំខ្លួន អៀង សារី ជាបណ្តោះអាសន្ន ដើម្បីធានាការរក្សាទុកគាត់សម្រាប់ដំណើរការតុលាការ[22]។

២៣. នៅក្នុងការកត់សំគាល់របស់ខ្លួន អៀង សារី មិនបានបង្ហាញភស្តុតាងថ្មីបន្ថែមទេលើចំនុចនេះ គឺលើកឡើងវិញតែទឡ្ហីករណ៍ដែលបានបង្ហាញអង្គបុរេជំនុំជម្រះរួចហើយប៉ុណ្ណោះ។ គាត់លើកឡើងថា អង្គបុរេជំនុំជម្រះ មិនបានគិតគូរពីកត្តាជាច្រើនដែលក្នុងនោះ "មានលក្ខណៈសមហេតុផលបំផុត" គឺថា ប្រពន្ធរបស់គាត់ដែលមានអាយុជិត ៨០ សិបឆ្នាំ ទៅហើយ និងមានសុខភាពមិនសូវល្អផង ដូច្នេះបើសិនជាគាត់រត់គេចខ្លួនទៅក្រៅប្រទេស គាត់នឹងមិនបានជួបប្រពន្ធគាត់ទៀតទេ[23]។

២៤. ទឡ្ហីករណ៍ទាំងនេះ មិនគ្រប់គ្រាន់ដើម្បីបង្ហាញថា ស្ថានភាព បានផ្លាស់ប្តូរទេចាប់តាំងពីថ្ងៃចេញសេចក្តីសម្រេចដោយអង្គបុរេជំនុំជម្រះ ដែលហេតុផលនៃសេចក្តីសម្រេចនេះ សហចៅក្រមស៊ើបអង្កេត យល់ស្របតាម។ ហេតុដូចនេះ ផ្អែកអង្គហេតុដែលបានរៀបរាប់ខាងលើ សហចៅក្រមស៊ើប

[20] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១០៤។

[21] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១០៥។

[22] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១០៦។

[23] C23/3 ការកត់សំគាល់របស់មេធាវីការពារក្តីប្រឆាំងនឹងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨, 00235370-00235379 (អង់គ្លេស) កថា. ១៦។

អង្កេត សន្និដ្ឋានថា ការរក្សាការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់មួយដើម្បីធានាវត្តមានរបស់ អៀង សារី នៅក្នុងគ្រប់ពេលនៃនីតិវិធី។

*ការពារសន្តិសុខរបស់ជនត្រូវចោទ*

២៥. នៅក្នុងការកត់សំគាល់របស់ខ្លួន អង្គបុរេជំនុំជម្រះ បានលើកឡើងថា អៀង សារី គឺជាអតីតឥស្សរជននយោបាយល្បីឈ្មោះមួយរូបនៅប្រទេសកម្ពុជា ដែលត្រូវបានចាត់ទុកថាជាមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ[24]។ លើសពីនេះទៀត ប្រការដែលមិនមានការប៉ុនប៉ងសងសឹក ឬការប្រឆាំងដោយការប្រើអំពើហិង្សាមុនពេលចាប់ខ្លួនគាត់ មានភាពត្រឹមត្រូវតិចតួចប៉ុណ្ណោះ។ ប៉ុន្តែ ការចាប់ខ្លួនគាត់ បានកាត់បន្ថយនូវអារម្មណ៍នៃនិទណ្ឌភាពដែលគាត់មាន[25]។ អង្គបុរេជំនុំជម្រះ បានកត់សំគាល់ឃើញពីការគំរាមកំហែងដែលបានស្តែងឲ្យឃើញយ៉ាងច្បាស់ប្រឆាំងនឹង ឌុច នៅពេលសវនាការជាសាធារណៈលើកដំបូង និង ដោយមានហេតុផលដែលគួរជឿបាន ថា អៀង សារី បានប្រព្រឹត្តបទឧក្រិដ្ឋដែលកើតមានឡើង និងបទឧក្រិដ្ឋទាំងឡាយដែលមានទំនាក់ទំនងជាមួយនឹងបទឧក្រិដ្ឋដែលចោទប្រកាន់ចំពោះ ឌុច នោះ បានសន្និដ្ឋានថា ការសំដែងនូវការគំរាមកំហែងដែលបានស្តាប់លឺនៅក្នុងសវនាការ ក៏អាចសំដៅទៅកាន់ អៀង សារី ផងដែរ[26]។

២៦. ហេតុដូច្នេះ អង្គបុរេជំនុំជម្រះ បានយល់ឃើញថា ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខរបស់ អៀង សារី[27]។

២៧. នៅក្នុងការកត់សំគាល់របស់ខ្លួន អៀង សារី អះអាងថា សេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំ-ជម្រះ បានឈរតែលើមូលដ្ឋានប្រដូចគ្នាទៅនឹងស្ថានភាពរបស់ ឌុច ប៉ុណ្ណោះ និងមិនបានគិតពីភាពខុស

[24] C22/I/73 អង្គបរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, 00232830-00232861 (អង់គ្លេស) កថា. ១០៧។

[25] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១០៨។

[26] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១០៩។

[27] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១១០។

គ្នារវាង ឌុច និងជនត្រូវចោទដទៃទៀតទេ[28]។ ប៉ុន្តែ ដូចការបកស្រាយរបស់អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា នៅពេលណាដែលទំនាក់ទំនង រវាងអង្គហេតុដែលបានចោទប្រកាន់ទៅលើ ឌុច និងបទឧក្រិដ្ឋដែលបានចោទប្រកាន់ចំពោះ អៀង សារី ត្រូវបានប្រកាសជាសាធារណៈ ពេលនោះ អ្នកដែលមានបំណងធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបស់ ឌុច ក៏អាចមានហេតុផលដូចគ្នា ក្នុងការធ្វើឲ្យប៉ះពាល់ដល់សន្តិសុខរបស់ អៀង សារី និងធ្វើការគំរាមកំហែងដល់រូបគាត់[29]។

២៨. ហេតុដូច្នេះ យោងតាមហេតុផលដូចបានរៀបរាប់ខាងលើ រួមទាំងហេតុផលរបស់អង្គបុរេ-ជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត យល់ឃើញថា ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីការពារសន្តិសុខរបស់ អៀង សារី។

*រក្សាសណ្តាប់ធ្នាប់សាធារណៈ*

២៩. បន្ទាប់ពីបានពិនិត្យលើឯកសារសំណុំរឿងរួចមក អង្គបុរេជំនុំជម្រះ បានឈានដល់ការសន្និដ្ឋានដូចខាងក្រោម ទាក់ទិននឹងភាពចាំបាច់ក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈ ៖

ក) ពេលវេលាដែលកន្លងផុតទៅ មិនបានកាត់បន្ថយផលប៉ះពាល់ដែលបង្កឡើងដោយរបបកម្ពុជា ប្រជាធិបតេយ្យ ចំពោះប្រទេសជាតិទេ។ ប្រជាជនកម្ពុជាមួយផ្នែកធំ ទទួលរងនូវរបួសផ្លូវចិត្តបន្ទាប់ពីការបញ្ចប់នៃរបបនេះ។ នីតិវិធីដែលកំពុងដំណើរការនៅចំពោះមុខ អ.វ.ត.ក អាចបង្ក

[28] C23/3 ការកត់សំគាល់របស់មេធាវីការពារក្តីប្រឆាំងនឹងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨, 00235370-00235379 (អង់គ្លេស) កថា. ១៩។

[29] C22/I/73 អង្គបរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, 00232830-00232861 (អង់គ្លេស) កថា. ១០៩។

ជាហានិភ័យក្នុងការដាស់ឡើងវិញនូវភាពចប់បារម្ភដែលដក់ជាប់នៅក្នុងសង្គមកម្ពុជា ហើយវាក៏អាចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សង្គមជាតិផងដែរ[30]។

ខ) មហាសន្និបាតអង្គការសហប្រជាជាតិ បានកត់សំគាល់ថា បទឧក្រិដ្ឋដែលបានកើតមានឡើងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅតែបន្តញាំញីសង្គមកម្ពុជា[31]។

គ) នីតិវិធីនៅចំពោះមុខ អ.វ.ត.ក បានបង្កើតឱ្យមានការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងចំណោមប្រជាជនកម្ពុជា ដែលនេះបង្ហាញឱ្យឃើញថា ព្រឹត្តិការណ៍ដែលបានកើតមានឡើងចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅពេលបច្ចុប្បន្ន នៅតែជាចំណុចចាប់អារម្មណ៍ខ្ពស់របស់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ[32]។

ឃ) វាមិនមែនជាការគ្មានហេតុផលទេដែលយើងមើលឃើញពីការគំរាមកំហែងដល់សន្តិសុខ[33]។

៣០. ដោយហេតុផលនេះហើយ អង្គបុរេជំនុំជម្រះបានយល់ឃើញថា ការដោះលែង អៀង សារី ឱ្យមានសេរីភាព នឹងធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ដូច្នេះ អង្គបុរេជំនុំជម្រះ បានសន្និដ្ឋានថា ការរក្សាការឃុំខ្លួនបណ្តោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីធានាសណ្តាប់ធ្នាប់សាធារណៈ។

៣១. សហចៅក្រមស៊ើបអង្កេត ប្រកាន់យកហេតុផលនេះ និងមើលឃើញពីអវត្តមាននៃភស្តុតាងទាំងឡាយដែលនាំឱ្យមើលឃើញថាស្ថានភាពបានផ្លាស់ប្តូរ ចាប់តាំងពីពេលសវនាការមក។ ដោយ

---

[30] C22/I/73 អង្គបុរេជំនុំជម្រះ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨, 00232830-00232861 (អង់គ្លេស) កថា. ១០៩។

[31] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១១៤។

[32] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១១៥។

[33] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១១៦។

ហេតុផលនេះ សហចៅក្រមស៊ើបអង្កេត សន្និដ្ឋានថា ការរក្សាការឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីធានាសណ្ដាប់ធ្នាប់សាធារណៈ[34]។

## ការឃុំខ្លួននៅក្នុងផ្ទះ

៣២. ទឡ្ហីករណ៍ចំបងដែល អៀង សារី បានដាក់ជូនអង្គបុរេជំនុំ ប្រឆាំងនឹងការឃុំខ្លួនគាត់ គឺថាការព្រួយបារម្ភទាំងឡាយទាក់ទិននឹងលក្ខខណ្ឌចាំបាច់កំណត់នៅក្នុងវិធាន ៦៣(៣)(ខ) នឹងលែងមានទៀតហើយ ប្រសិនបើ អង្គជំនុំជម្រះវិសាមញ្ញ យល់ព្រមឱ្យមានការសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ ឬការឃុំខ្លួននៅក្នុងផ្ទះ។

៣៣. អង្គបុរេជំនុំជម្រះ បានយល់ឃើញថា វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញ មិនមានបទប្បញ្ញត្តិពិសេសណាមួយចែងអំពីទំរង់ដែលជំនួសការឃុំខ្លួនទេ និងបានបកស្រាយសំណើសុំរបស់ អៀង សារី ដូចជា "ការស្នើសុំដោះលែងឱ្យមានសេរីភាពរួមជាមួយការសម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ ឬការដាក់ឃុំខ្លួននៅក្នុងផ្ទះ"[35]។

៣៤. បន្ទាប់មកទៀត អង្គបុរេជំនុំជម្រះ បានយល់ឃើញថា៖

ក) ដោយយល់ឃើញថា ការរក្សាឃុំខ្លួនបណ្ដោះអាសន្ន គឺជាវិធានការចាំបាច់ដើម្បីធានាសន្តិសុខរបស់ អៀង សារី និងការរក្សារូបគាត់សម្រាប់ដំណើរការតុលាការ ព្រមទាំងការរក្សារបៀបរៀបរយសាធារណៈផង ដូច្នេះ សាមីខ្លួនមិនអាចត្រូវបានដោះលែងឱ្យមានសេរីភាព ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការទេ ពីព្រោះ ចរិតលក្ខណៈចាំបាច់នៃការឃុំខ្លួនមានប្រៀបជាងរាល់ការធានាដែលជនត្រូវចោទផ្ដល់មក[36]។

---

[34] នៅក្នុងសេចក្ដីសម្រេចដដែល កថា. ១១៧។

[35] នៅក្នុងសេចក្ដីសម្រេចដដែល កថា. ១១៩-១២០។

[36] នៅក្នុងសេចក្ដីសម្រេចដដែល កថា. ១២១។

ខ) ទោះបីជា អៀង សារី សម្រាកព្យាបាលជម្ងឺនៅមន្ទីរពេទ្យ ឬស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការក៏ដោយ ក៏សន្តិសុខផ្ទាល់ខ្លួនរបស់គាត់ នៅតែអាចស្ថិតនៅក្នុងគ្រោះថ្នាក់ដដែល។ គាត់នឹងធ្វើដំណើរមកអង្គជំនុំជម្រះវិសាមញ្ញ សម្រាប់ហេតុផលផ្សេងៗ ហើយវានឹងមានការលំបាកក្នុងការធានាសន្តិសុខរបស់គាត់ នៅក្នុងកំឡុងពេលនៃការដឹកជញ្ជូនពីមន្ទីរពេទ្យ ឬពីគេហដ្ឋាន ទៅអង្គជំនុំជម្រះ ដើម្បីចូលរួមក្នុងសវនាការសាធារណៈនានាដែលពាក់ព័ន្ធនឹងខ្លួន[37]។

៣៥. នៅក្នុងការកត់សំគាល់របស់ខ្លួន អៀង សារី គូសបញ្ជាក់ថា ប្រសិនបើខ្លួនជាកម្មវត្ថុនៃការដាក់ឱ្យស្ថិតនៅក្រោមវិធានការឃុំខ្លួននៅក្នុងផ្ទះ ដោយភ្ជាប់ជាមួយលក្ខខណ្ឌចាំបាច់នោះ មិនត្រូវមានការព្រួយបារម្ភទាក់ទិននឹងសន្តិសុខរបស់ខ្លួន ពីការធានាវត្តមានរបស់ខ្លួនសម្រាប់តុលាការ ឬការថែរក្សារបៀបរៀបរយសាធារណៈទេ[38]។ ក្នុងរឿងនេះ គាត់មិនបានបង្ហាញភស្តុតាងថ្មីណាមួយដើម្បីគាំទ្រដល់ការអះអាងនេះទេ គឺបានត្រឹមតែរំលឹកឡើងវិញ និងធ្វើការអត្ថាធិប្បាយបន្ថែមពីការកត់សំគាល់ដែលខ្លួនបានដាក់ជូនអង្គបុរេជំនុំជម្រះ រួចហើយ និងវាយប្រហារទៅលើសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះប៉ុណ្ណោះ។

៣៦. សហចៅក្រមស៊ើបអង្កេត បានធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួនច្បាស់ពីសេចក្តីសន្និដ្ឋានរបស់អង្គបុរេជំនុំជម្រះ និងបញ្ជាក់បន្ថែមថា ខ្លួនមិនមើលឃើញមានលក្ខខណ្ឌ*សមហេតុផល* ណាមួយដែលភ្ជាប់ជាមួយនឹងការឃុំខ្លួននៅក្នុងផ្ទះ អាចធានាបាននូវលក្ខខណ្ឌកំណត់នៅក្នុងវាក្យខណ្ឌ ៣ ដល់វាក្យខណ្ឌ ៥ នៃវិធាន ៦៣(៣)(ខ) ដូចវិធានការឃុំខ្លួនបណ្តោះអាសន្នទេ។ ក្រៅពីនេះ សហចៅក្រមស៊ើបអង្កេត កត់សំគាល់ឃើញថា វាជាការចាំបាច់ដែលលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌប្រាំដែលមានចែងនៅក្នុងវិធាន ៦៣(៣)(ខ) ត្រូវបានបំពេញដើម្បីឱ្យវិធាននេះអាចអនុវត្តបាន និងថាចំពោះរឿងនេះ សហចៅក្រមស៊ើបអង្កេត សម្រេចយកលក្ខខណ្ឌចំនួនបី។

---

[37] នៅក្នុងសេចក្តីសម្រេចដដែល កថា. ១២២។

[38] C23/3 ការកត់សំគាល់របស់មេធាវីការពារក្តីប្រឆាំងនឹងការពន្យារពេលការឃុំខ្លួនបណ្តោះអាសន្ន អៀង សារី ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨, 00235370-00235379 (អង់គ្លេស) កថា. ១៨, ២២, ២៦។

## ការកន្លងផុតនៃពេលវេលា

៣៧. ពេលវេលាដែលកន្លងផុតទៅ គឺជាកត្តាមួយសម្រាប់យកមកធ្វើការពិចារណា ដើម្បីសម្រេចពីលក្ខណៈសមស្របនៃការរក្សាការឃុំខ្លួនបណ្ដោះអាសន្នរបស់ជនត្រូវចោទ។ ពេលវេលានៃការឃុំខ្លួនបណ្ដោះអាសន្នដែលកន្លងផុតទៅ នឹងមិនត្រូវបានចាត់ទុកថាមិនត្រឹមត្រូវទេ ប្រសិនបើមានភស្តុតាងបង្ហាញថា នីតិវិធីប្រព្រឹត្តទៅដោយមានការយកចិត្តទុកដាក់។ ដើម្បីវាយតម្លៃពីរបៀបដឹកនាំនៃកិច្ចស៊ើបសួរនេះ និងដោយប្រៀបធៀបទៅនឹងយុត្តិសាស្ត្ររបស់តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស លើបញ្ហារយៈពេលសមស្រប សហចៅក្រមស៊ើបអង្កេត យល់ឃើញថា វាជាការចាំបាច់ដែលត្រូវគិតដល់អង្គហេតុទាំងមូល និងជាពិសេសអំពីភាពស្មុគស្មាញខាងអង្គហេតុ និងអង្គច្បាប់នៃរឿងក្ដី ការប្រព្រឹត្តរបស់អាជ្ញាធរតុលាការ និងឥរិយាបថរបស់ភាគី[39]។

៣៨. នៅក្នុងរឿងនេះ ជនត្រូវចោទ ត្រូវបានជាប់ឃុំអស់រយៈពេលប្រមាណជាជិត ១២ ខែ។ រយៈពេលនេះ មិនមានលក្ខណៈហួសហេតុទេ បើគិតពីទំហំធំនៃកិច្ចស៊ើបសួរ ភាពស្មុគស្មាញ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបញ្ជូនមកសហចៅក្រមស៊ើបអង្កេត[40]។

៣៩. ចាប់តាំងពីបើកការស៊ើបសួរមក សហចៅក្រមស៊ើបអង្កេត បានដឹកនាំការស៊ើបអង្កេតទៅលើបទឧក្រិដ្ឋទាំងនេះ។ ហេតុនេះហើយ ចាប់តាំងពីសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នមកសហចៅក្រមស៊ើបអង្កេត បានប្រមូលភស្តុតាងជាច្រើន ទៅតាមសំណើសុំរបស់ភាគីនានា ឬទៅតាមការផ្ដួចផ្ដើមរបស់ខ្លួនផ្ទាល់ និងបានសួរចម្លើយជនត្រូវចោទផ្សេងទៀត ជាពិសេសអំពីតួនាទី របស់

---

[39] CEDH, ដីកា *Frydlender ទល់នឹង France* ចុះថ្ងៃទី ២៧ មិថុនា ២០០០, លេខ ៤៣; CEDH ដីកា *Pelissier និង Sassi ទល់នឹង France* ចុះថ្ងៃទី ២៥ ខែមីនា ឆ្នាំ ១៩៩៩ , លេខ ៧១; CEDH ដីកា *Vernillo ទល់នឹង France* ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ១៩៩១, លេខ ៣៤។

[40] នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់ខ្លួន សហព្រះរាជអាជ្ញាបានបើកការស៊ើបអង្កេតបឋម លើបុគ្គលប្រាំរូប ចំពោះអំពើដែលបានប្រព្រឹត្ត នៅលើទឹកដីកម្ពុជាទាំងមូលក្នុងអំឡុងពេលដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ អ.វ.ត.ក និងបានស្នើបទចោទប្រកាន់បទឧក្រិដ្ឋជាតិ និងអន្តរជាតិជាច្រើន និងស្មុគស្មាញ [លុប]។

អៀង សារី។ កំណត់ហេតុស្ដាប់ចម្លើយសាក្សីចំនួន ១៤៦ ត្រូវបានដាក់ចូលក្នុងសំណុំរឿង ដែលក្នុងចំណោមនោះ មានមួយចំនួនបានផ្ដល់ព័ត៌មានអំពីតួនាទីដែលជនត្រូវចោទមាននៅក្នុងរបប។

៤០. ជាពិសេសនៅក្នុងអំឡុងពេលនៃការស្ដាប់យកចម្លើយនៅថ្ងៃទី [លុប] សាក្សី [លុប] ក្នុងនោះបានបញ្ជាក់ថា អៀង សារី បានដឹងពីការបោសសំអាតទ្រង់ទ្រាយធំនៅក្រសួងការបរទេស និងមានតួនាទីជាអ្នកសម្រេចនៅក្នុងក្រសួងរបស់ខ្លួន[41]។

៤១. លើសពីនេះទៀត ដីកាចាត់ឲ្យស៊ើបសួរជំនួសជាច្រើនកំពុងត្រូវបានអនុវត្ត។ ជាចុងក្រោយជនត្រូវចោទក៏ត្រូវបានសួរចម្លើយផងដែររហូតដល់ពេលដែលខ្លួនរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយ។ សិទ្ធិនៅស្ងៀម គឺជាសិទ្ធិត្រូវបានទទួលស្គាល់ និងមិនអាចជំទាស់បាន ប៉ុន្តែការធ្វើដូច្នេះ វាមិនបានចូលរួមចំណែកដល់ការពន្លឿននីតិវិធីទេ។

---

[41] [លុប]។

៤២. យោងតាមការបកស្រាយខាងលើ ពេលវេលាដែលកន្លងផុតទៅ មិនបានធ្វើឱ្យប៉ះពាល់ដល់ចរិតលក្ខណៈចាំបាច់នៃការរក្សាការឃុំខ្លួនបណ្ដោះអាសន្ននោះទេ។

៤៣. សហចៅក្រមស៊ើបអង្កេតយល់ឃើញថា វាមានហេតុផលសមស្រប ដែលអាចនាំឱ្យជឿបានថា អៀង សារី បានប្រព្រឹត្តបទឧក្រិដ្ឋដែលគាត់ត្រូវបានចោទប្រកាន់ ហើយដោយយោងទៅលើសំអាងហេតុផល ដែលបានរៀបរាប់ខាងលើ វាជាការចាំបាច់ដែលត្រូវរក្សា អៀង សារី ឱ្យបន្តនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្ន។

## អាស្រ័យហេតុនេះ

**សម្រេច** បន្តរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន **អៀង សារី** ក្នុងរយៈពេលអតិបរមាចំនួនមួយឆ្នាំបន្ថែមទៀត ដោយអនុលោមតាមបទប្បញ្ញត្តិនៃវិធាន ៦៣.៦.ក). នៃវិធានផ្ទៃក្នុង។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៨

**សហចៅក្រមស៊ើបអង្កេត**

**Co-Investigating Judges**

**Co-juges d'instruction**